# សាលារៀនជំនាន់ថ្មី វិទ្យាល័យព្រះយុគន្ធរ




ជំពូកទី២ ប្រវត្តិសាស្ត្រកម្ពុជា

មេរៀនទី១ ប្រទេសកម្ពុជាក្រោមអាណានិគមយនិមបារាំង

(១៨៦៣ ដល់ ១៩៥៣) (ម៉ោងទី២)

ថ្នាក់ទី១២

ឆ្នាំសិក្សា៖ ២០២៤ - ២០២៥



**រំឭកមេរៀនចាស់**

តើមូលហេតុអ្វីខ្លះនាំឱ្យមាការចុះសន្ធិសញ្ញាអាណាព្យាបាល
បារាំង-ខ្មែរ ថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៨៦៣?

# មូលហេតុដែលនាំឱ្យមាការចុះសន្ធិសញ្ញាអាណាព្យាបាល បារាំង-ខ្មែរ ថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៨៦៣គឺ

- ✓ ប្រទេសកម្ពុជានៅអំឡុងពេលនោះជាប្រទេសទន់ខ្សោយ ទទួលរងការគម្រាមគំហែងពីប្រទេសជិតខាងគឺ សៀម និងអាណ្ណាម។
- ✓ កម្ពុជាត្រូវការប្រទេសមហាអំណាចធំៗដើម្បីការពារអធិបតេយ្យភាព និងបូរណភាពដែនដីរបស់ខ្លួន។
- ✓ ព្រះបាទអង្គដួងទទួលបានការបំភ្លឺពីឥទ្ធិពល និងកម្លាំងរបស់បារាំងតាមរយៈបព្វជិតសាសនាបារាំង ឈ្មោះមីស។
- ✓ ព្រះបាទអង្គដួង ចង់ធ្វើទំនើបកម្មអភិវឌ្ឍប្រទេស ដូចបារាំងដែរ។

# មូលហេតុដែលនាំឱ្យមានការចុះសន្ធិសញ្ញាអាណាព្យាបាលបារាំង-ខ្មែរ ថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៨៦៣គឺ

- ✓ បារាំងបានជក់ចិត្តនិងសម្រស់នៃប្រទេសកម្ពុជា ដែលមានទេសភាពខៀវស្រងាត់ និងអាចដាំដុះផលិតផលកសិកម្មជាច្រើន។ ដែលអាចបម្រើឱ្យសេដ្ឋកិច្ចរបស់ខ្លួន។
- ✓ កម្ពុជាមានប្រភពទឹកសម្បូរបែប ជាផ្លូវគមនាគមន៍យ៉ាងសំខាន់សម្រាប់ការធ្វើជំនួញ។
- ✓ មើលឃើញពីសក្តានុពលកសិកម្មរបស់កម្ពុជា ជាពិសេសផ្ទៃដីដាំដុះស្រូវដែលមានចំនួនច្រើន ប៉ុន្តែមានចំនួនប្រជាជនតិច។
- ✓ បានដឹងពីធនធានរ៉ែ និងធនធានធម្មជាតិយ៉ាងសម្បូរបែប ដែលអាចឱ្យបារាំងទាញយកទៅប្រើប្រាស់ក្នុងពេលអនាគត។ (ចម្លើយផ្សេងទៀត)















តើរូបភាពទាំងនេះ បង្ហាញអ្វីដល់ប្អូនៗទាំងអស់គ្នា?

# <u>សំណួរពិភាក្សា</u>

១. តើមូលហេតអ្វីខ្លះ នាំឱ្យប្រទេសកម្ពុជាទទួលបានឯករាជ្យពីបារាំង?

២. តើស្ថិតក្រោម អាណាព្យាបាលបារាំង ប្រទេសកម្ពុជាទទួលបានផលអ្វីខ្លះ?





# តើមូលហេតុអ្វីខ្លះ ដែលនាំឱ្យកម្ពុជាទទួលបានឯករាជ្យពីបារាំង ?

៩ វិច្ឆិកា ១៩៥៣

កត្តាខាងក្នុង

- ចលនាខ្មែរឥស្សរៈ
- រាជបូនីយកម្មរបស់សម្តេចសីហនុ

កត្តាខាងក្រៅ

- បារាំង
- អាមេរិក និងសហភាពសូវៀត



កត្តាខាងក្នុង




- **ការតស៊ូទាមទារឯករាជ្យដោយសន្តិវិធី ៖**
  - ព្រះរាជបូជនីយកិច្ចរបស់ព្រះបាទនរោត្តមសីហនុ។ ដោយការធ្វើនយោបាយការទូតទៅប្រទេសបារាំង កាណាដា សហរដ្ឋអាមេរិក និងប្រទេសថៃ។
  - ប្រជាពលរដ្ឋ មានស្មារតីមោះមុត ក្នុងការទាមទារឯករាជ្យពីបារាំង។
- **ការតស៊ូប្រដាប់អាវុធ៖**
  - ខ្មែរឥស្សរៈសេរី និងកុម្មុយនិស្ត៖ ជាចលនាតស៊ូទាមទារឯករាជ្យដោយប្រើអាវុធ ធ្វើការប្រយុទ្ធបង្ករឈាមដើម្បីបណ្តេញបារាំងចេញពីទឹកដី។ ក្រុមនេះបានកាន់កាប់ទឹកដី១/៣នៃប្រទេសកម្ពុជា នៅឆ្នាំ១៩៤៩។



កត្តាខាងក្រៅ

បារាំង

▪ចលនារើបម្រះទាមទារឯករាជ្យអន្តរជាតិ របស់បណ្តាប្រទេសដែលស្ថិតនៅក្រោមអាណានិគមបារាំង ពាសពេញពិភពលោក។

▪នយោបាយ និងសេដ្ឋកិច្ចបារាំង បានខូចខាតខ្លាំងដោយសារសង្គ្រាមលោកលើកទី២ ដូចនេះបារាំងមិនអាចប្រើប្រាស់នយោបាយតឹងរឹងដូចកាលពីមុនទៀយ។ ជាពិសេស ការប្រឈមមុខជាមួយមហាអំណាចពិភពលោកថ្មី គឺសហរដ្ឋអាមេរិក និងសហភាពសូវៀត។

ពិភពលោក

▪ អង្គការសហប្រជាជាតិ (UN) បានអំពាវនាវឲ្យប្រទេសអាណានិគមនិយម ផ្តល់ស្វ័យភាព និងឯករាជ្យដល់ម្ចាស់ប្រទេសវិញ។

▪ សហរដ្ឋអាមេរិក និងសូវៀត មាននយោបាយគាំទ្រដល់ការផ្តល់ឯករាជ្យ គ្រប់ប្រទេសទាំងអស់។

▪នយោបាយអាណានិគម ក្លាយជានយោបាយហួសសម័យ។



# ២. តើស្ថិតក្រោម អាណាព្យាបាលបារាំង ប្រទេសកម្ពុជាទទួលបានផលអ្វីខ្លះ ?

ផលវិជ្ជមាន

ផលដែលកម្ពុជា
ទទួលបានពីបារាំង

ផលអវិជ្ជមាន



# ផលវិជ្ជមាន

- បារាំងជួយការពារទឹកដី និងជនជាតិខ្មែរឲ្យបានគង់វង្ស និងរួចផុតពីមហិច្ឆតា ឈ្លានពានលេបត្របាក់យកទឹកដីខ្មែរ ពីសំណាក់ប្រទេសជិតខាង។
- បារាំងបានបង្កើតសាលាចុងបូព៌ាប្រទេស ដើម្បីសិក្សាស្រាវជ្រាវ និងចងក្រងពីអរិយធម៌ ប្រវត្តិសាស្ត្រខ្មែរ សម្រាប់កូនចៅខ្មែរជំនាន់ក្រោយ។
- ក្រោមការគាបសង្កត់របស់បារាំង សៀមបានប្រគល់មកវិញនូវខេត្តស្ទឹងត្រែង ទន្លេរពៅ ម្លូព្រៃ កោះកុង (១៩០៤) បាត់ដំបង សៀមរាប និងសិរីសោភ័ណ្ឌ(១៩០៧)ឲ្យខ្មែរវិញ។
- គូសផែនទីដងរ៉ែក ដែលជាព្រំដែនរវាងកម្ពុជា និងថៃក្នុងឆ្នាំ១៩០៨ ហើយត្រូវបានទទួល ស្គាល់ជាអន្តរជាតិរហូតដល់សព្វថ្ងៃ។
- វិស័យសិក្សាធិការ ៖ ផ្លាស់ប្តូរពីការអប់រំតាមបែបប្រពៃណី (បួសរៀនតាមវត្ត) មកជាប្រព័ន្ធអប់រំបែបទំនើប មានសាលារៀនពីបឋម ដល់វិទ្យាល័យ។

# ផលវិជ្ជមាន

- នៅឆ្នាំ១៩១៥មានការបង្កើតគណកម្មាធិការរៀបចំវចនានុក្រមខ្មែរ ដើម្បីធ្វើឲ្យភាសាជាតិមានលក្ខណៈប្រាកដនិយម។
- វិស័យសង្គម៖ បារាំងបានកែទម្រង់រដ្ឋបាល តុលាការ និងពន្ធដារ ឲ្យមានហេដ្ឋារចនាសម្ព័ន្ធ ល្អប្រសើរ និងមានច្បាប់ទម្លាប់ជាក់លាក់។ ចំណែករបបទាសភាពវិញ ក៏លុបបំបាត់ចេញពីសង្គមខ្មែរផងដែរ។
- វិស័យសេដ្ឋកិច្ច៖ បារាំងនាំចូលដំណាំកសិឧស្សាហកម្មជាច្រើនដូចជា៖ ដូចជាកៅស៊ូ ម្រេច ក្រចៅ ថ្នាំជក់ជាដើម។
- វិស័យពាណិជ្ជកម្ម ៖ បារាំងបង្កើតឲ្យមានធនាគារ ហាងលក់ទំនិញធំ ហាងបញ្ចាំ និងទីផ្សារជាដើម។
- វិស័យគមនាគមន៍៖ កសាងស្ពាន ផ្លូវថ្នល់ និងផ្លូវដែក ពីភ្នំពេញកាត់តាមអារញ្ញទៅប៉ោយប៉ែត។
- វិស័យសុខាភិបាល៖ បានបង្កើតមន្ទីរពេទ្យសម្រាប់ព្យាបាល កម្មករនៅតាមចម្ការកៅស៊ូ។








២០២០
១៩២០





# ផលអវិជ្ជមាន

- បារាំងបានលុបបំបាត់របបទាសភាពមែន  ប៉ុន្តែជីវភាពប្រជាជនខ្មែរពុំបានប្រសើរទេ  ផ្ទុយទៅវិញមានការធ្វើទុក្ខបុកម្នេញ ទារការប្រមូលពន្ធដារគ្រប់សណ្ឋានដែលធ្វើឲ្យរាស្ត្រខ្មែរកាន់តែក្រីក្រ។
- នៅក្នុងសង្គ្រាមលោកលើកទី១ និងទី២ បារាំងបានកេណ្ឌប្រជាជនកម្ពុជាធ្វើជាទាហានដែលបណ្តាលឲ្យមានមនុស្សបាត់បង់ជីវិតជាច្រើន។






# ផលអវិជ្ជមាន (ត)

- ក្នុងឆ្នាំ១៩៤៩ បារាំងបានកាត់ទឹកដីកម្ពុជាក្រោម និងដាទ្បាត់ឲ្យប្រទេសវៀតណាមខាងត្បូង (ស្តេចបាវដាយ)។
- តាមរយៈសន្ធិសញ្ញាបារាំង-សៀម ឆ្នាំ១៩០៧ ខេត្តត្រាត ត្រូវបានបារាំងប្រគល់ឲ្យសៀម។
- បារាំងប្រមូលវត្ថុកេតនភណ្ឌមានតម្លៃរបស់ខ្មែរទៅស្រុកបារាំង។
- បន្សល់ទុកនូវភាពមិនច្បាស់លាស់នៃព្រំដែនជាមួយប្រទេសជិតខាង ដែលក្លាយជាបញ្ហាទំនាស់រហូតមកដល់ពេលសព្វថ្ងៃ។






[illegible]

១. តើប្រទេសកម្ពុជាទទួលបានឯករាជ្យពីបារាំងនៅថ្ងៃខែឆ្នាំណា ?

ក. ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥១

ខ. ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥២

គ. ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣

ឃ. ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៤



[illegible]

២. តើចលនាតស៊ូឯករាជ្យនៅក្នុងកម្ពុជាមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?

ក. ១ គឺ ចលនាខ្មែរឥស្សរៈ

ខ. ១ តាមផ្លូវទូត របស់សម្តេច នរោត្តម សីហនុ

គ. ៣ប្រភេទ គឺខ្មែរសេរី ខ្មែរកុម្មុយនិស្ត និងការទូត

ឃ. ចម្លើយ ក និងខ

# ពង្រឹងពុទ្ធិ

**២. តើផែនទីភ្នំដងរែក ត្រូវបានគូសឡើងនៅឆ្នាំណា?**




ក. ១៩០៧

ខ. ១៩០៨

គ. ១០៩០

ឃ. ១៩១០

# សូមអរគុណ

